តុលាការខេត្តកំពង់ធំ

សាលក្រម

លេខ ៣២ "ក" ចុះថ្ងៃទី ២៨

ខែ កក្កដា ឆ្នាំ ២០០៥

សំណុំរឿង

លេខ ៦៩ ចុះថ្ងៃទី ១៧

ខែ ឧសភា ឆ្នាំ ២០០៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### តាងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ ប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ តទៅ
ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។
កំពង់ធំ, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥
ប្រធានតុលាការខេត្ត
[redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៦៩ ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំលែងលះប្តី, សុំគ្រប់គ្រងកូនចំនួន ០២នាក់, ទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៥០០ដុល្លា និង សុំចែកទ្រព្យសម្បត្តិតាមច្បាប់ ។**

-រវាងដើមចោទ **ប មរ** ភេទស្រី អាយុ ៣០ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃនៅភូមិទី ៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ប្តីឈ្មោះ **ស ទណ** មានកូន ០២នាក់ ឪពុកឈ្មោះ **ប គស** (រ) ម្តាយឈ្មោះ **ល សអ** "រ" ។

-និង ចុងចម្លើយឈ្មោះ **ស ទណ** ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ សព្វថ្ងៃនៅភូមិទី៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ របររកស៊ីគ្រូបង្រៀន ប្រពន្ធឈ្មោះ **ប មរ** មានកូន ០២នាក់ ឪពុកឈ្មោះ **ម អ** "រ" ម្តាយឈ្មោះ **ន យ** "រ" ។

### ងរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ **ប មរ** បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ **ស ទណ** សុំគ្រប់គ្រងកូន ០២នាក់ ទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនផ្តាច់ ៥០០ដុល្លា និង សុំចែកទ្រព្យសម្បត្តិតាមច្បាប់ ដោយសំអាងហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ **ស ទណ** ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់តាំងពីឆ្នាំ ១៩៩៧ ការរស់នៅជាមួយគ្នាបានកូន ០២នាក់ហើយ

ក្រោយមកប្តីមានស្រីថ្មី រហូតបានកូនម្នាក់ទៀត ទើបប្តឹងសុំលែងលះនេះ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៣៨០ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៣៨១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០៥ ។

## នារពេលសទនាភារ

-ដើមចោទឈ្មោះ **ម ម** បានឆ្លើយបញ្ជាក់ថា ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយជាប្តីប្រពន្ធ និង គ្នាត្រឹមត្រូវតាមប្រពៃណីពីឆ្នាំ ១៩៩៧ រួមរស់នៅជាមួយគ្នាមានកូន ០២នាក់ កូនទី១ ឈ្មោះ **ថ សទទត** ភេទស្រី អាយុ ០៧ឆ្នាំ និង កូនទី២ ឈ្មោះ **ទ មនន** ភេទស្រី អាយុ ០៣ឆ្នាំ ។ កន្លងមកការរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ បានសុខសាន្តធម្មតា តែត្រឹមខ្លួនមានផ្ទៃពោះកូនទី២ បាន ០៨ខែ ប្តីបានទៅទំនាក់ទំនងស្រីផ្សេងរហូត ខ្លួនឆ្លងទន្លេ កូនទី២បានជិត ០៦ខែ ទើបដឹងប្តីមានសាហាយ ហើយខ្លួនបានព្យាយាមលួងលោមអូសទាញប្តីឱ្យវិលវិញ ហើយ ទាំងចាស់ទុំក៏បានជួយណែនាំដែរ តែប្តីនៅតែស្និទ្ធស្នាលជាមួយស្រីថ្មីនោះរហូតមានកូនប្រុសម្នាក់ទៀតផង មិនតែ ប៉ុណ្ណោះប្តីបានប្រើអំពើហិង្សាវាយដំមកលើខ្លួន និង មើលងាយឪពុកម្តាយថែមទៀត ជាហេតុធ្វើអោយអស់ មនោសញ្ចេតនានឹងរួមរស់នៅជាប្តីប្រពន្ធនឹងគ្នាហើយ សុំឱ្យបានលែងលះពីប្តីតាមច្បាប់ ។ ទ្រព្យសម្បត្តិដើមមានដី លំនៅដ្ឋានទំហំ ៤,២០ម x ១៨ម ស្ថិតនៅភូមិទី៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឯទ្រព្យសម្បត្តិរួម មានផ្ទះឈើប្រក់សង្កសីទំហំរួម ៤,២០ម x១៨ម ឥវ៉ាន់លក់ដូរមួយចំនួន ម៉ូតូហុងដាសេ១០០ ឆ្នាំ ២០០៤ ចំនួន ០១គ្រឿងតំលៃ ៩៥០ដុល្លា លុយទិញម៉ូតូនេះបានខ្ចីពីម្តាយក្មេកចំនួន ៣០០ដុល្លា,កុំព្យូទ័រ ០១គ្រឿង, ម៉ាស៊ីនព្រីន ០១គ្រឿង, ទូរទស្សន៍ពណ៌ចំនួន ០២គ្រឿង, ក្បាលវីស៊ីឌី ០១គ្រឿង, ម៉ាញ៉េ ០១គ្រឿង, ជំពាក់អេស៊ីលីដា ៣០០ដុល្លា អាមេរិក ។ សំណូមពរសុំលែងលះប្តី ដោយសុំបែងចែកកូនស្មើគ្នា មិនទាមទារអាហារកិច្ចទេ និង សុខចិត្តប្រគល់ ប្រាក់ ៩០០ ដុល្លាអាមេរិក ម៉ូតូហុងដាសេ១០០ឆ្នាំ ២០០៤ ចំនួន ០១គ្រឿង តុបង្រៀនសិស្សចំនួន ២០ តុកុំព្យូទ័រ ០១ គ្រឿង និង ម៉ាស៊ីនព្រីនធ័រ ០១គ្រឿងអោយទៅចុងចម្លើយ ឯទ្រព្យសម្បត្តិរួមក្រៅពីនេះសុំគ្រប់គ្រងផ្ទាល់ខ្លួន ។

-ចុងចម្លើយឈ្មោះ **ស ទណ** បានឆ្លើយបញ្ជាក់ថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ **ម ម** ត្រឹមត្រូវតាមប្រពៃណីតាំងពីឆ្នាំ ១៩៩៧ មកដូចចម្លើយដើមចោទ ។ ការរួមរស់នៅជាមួយគ្នាកន្លងមកមានកូន ០២នាក់ ទី១ ឈ្មោះ **ថ សទទត** ភេទស្រី អាយុ ០៧ឆ្នាំ និង ទី២ ឈ្មោះ **ទ មនន** ភេទស្រី អាយុ ០៣ឆ្នាំ បាន សេចក្តីសុខជាធម្មតា លុះមកដល់ឆ្នាំ ២០០៣ ខ្លួនបានស្រលាញ់នារីម្នាក់ដោយលួចលាក់មិនឱ្យប្រពន្ធដឹង តែមានថ្ងៃ មួយប្រពន្ធមកទាន់ឃើញខ្លួនកំពុងនិយាយជាមួយនារីនោះនៅតាមផ្លូវសាធារណៈ ក៏កើតមានជម្លោះគ្នាតាំងពីពេល នោះមក ហើយប្រពន្ធបានជេរប្រមាថធ្វើឱ្យខ្លួនបាត់បង់កិត្តិយស រហូតដល់ឆ្នាំ ២០០៣ ខ្លួនក៏បែកលំនៅសង្វាសពី ប្រពន្ធប្រហែល ០៥ខែទៅរស់នៅជាមួយម្តាយឯភ្នំពេញ លុះក្រោយមកបានដឹងថា ជីវភាពគ្រួសារចុះដុនដាបក៏ ត្រឡប់មកស្តារសេដ្ឋកិច្ចគ្រួសារវិញ តែដោយខ្លួនបានលួចជួបនារីកំណាន់ចិត្ត ប្រពន្ធដឹងខឹងក៏ប្តឹងមកតុលាការនេះ ។ ទ្រព្យសម្បត្តិដើមខ្លួនគ្មានទេ ឯទ្រព្យសម្បត្តិរួមមានផ្ទះឈើប្រក់សង្កសីទំហំ ៤,២០ម x ១៨ម សង់លើដីដែលខ្លួន បានទិញពីម្តាយក្មេកតំលៃ ៤.៥០០ដុល្លា បានសងទៅគាត់ចំនួន ២.០០០ដុល្លា នៅខ្វះ ២.៥០០ដុល្លាមិនទាន់សង ដីនេះទំហំ ៤,២០ម x១៨ម ស្ថិតនៅភូមិទី៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឥវ៉ាន់លក់ដូរជាភេសជ្ជៈមួយ ចំនួន, ម៉ូតូហុងដាសេ១០០ ឆ្នាំ ២០០៤ ចំនួន០១គ្រឿង ខ្ចីលុយម្តាយខ្លួនចំនួន ៥០០ដុល្លាអាមេរិកមកទិញ កុំព្យូទ័រ ០១គ្រឿង, ម៉ាស៊ីនព្រីនធ័រ ០១គ្រឿង, ទូរទស្សន៍ពណ៌ចំនួន ០២គ្រឿង, ក្បាលវីស៊ីឌី ០១គ្រឿង, ម៉ាញ៉េ ០១គ្រឿង, ទូរស័ព្ទ ០២គ្រឿង, ទូកញ្ចក់លក់ភេសជ្ជៈ, តុបាយចំនួន ០៧គ្រឿង ។ សំណូមពរសុំអោយបានដាច់សមត្ថសង្វាសពី

ប្រពន្ធ ដោយយល់ព្រមឯកភាពតាមដើមចោទក្នុងការបែងចែកកូន និង ទ្រព្យសម្បត្តិ ។

**តំណាងអយ្យការធ្វើសន្និដ្ឋានថា :**

ចំពោះរឿងក្ដីនេះអយ្យការស្នើសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្ដាប់ដើមចោទឆ្លើយអោយការណ៍ និង ប្ដឹងសុំ

-ក្រោយពីបានស្ដាប់ចម្លើយដោះសាររបស់ចុងចម្លើយ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការខេត្តកំពង់ធំ**

-យល់ឃើញថា : ពាក្យបណ្ដឹងចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៩ របស់ដើមចោទឈ្មោះ **ម មរ** មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ **ម មរ** បានប្ដឹងសុំផ្ដាច់សមគ្គសង្វាសពីប្ដីឈ្មោះ **ស ខណា** ដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយចុងចម្លើយជាប្ដីប្រពន្ធនឹងគ្នា តាំងពីឆ្នាំ១៩៩៧ រួមរស់នៅជាមួយគ្នាមានកូន ០២នាក់ ប្ដីបានលួចលាក់មានស្រីថ្មីរហូតមានកូន ០១នាក់ទៀតធ្វើឱ្យខ្លួនអស់មនោសញ្ចេតនារួមរស់ជាប្ដីប្រពន្ធតទៅទៀតហើយ ។

-យល់ឃើញថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាប្ដីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ពីឆ្នាំ ១៩៩៧ រួមរស់នៅជាមួយគ្នាបានកូន ០២នាក់ ចុងចម្លើយទៅមានស្រីថ្មី ហើយស្ម័គ្រចិត្តលែងលះដោយអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា : គូភាគីបានឯកភាពគ្នាទទួលគ្រប់គ្រងចិញ្ចឹមកូនមួយម្នាក់ ដោយដើមចោទសុំយកកូនបង និង ចុងចម្លើយសុំយកកូនប្អូន មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-យល់ឃើញថា ទ្រព្យសម្បត្តិដើមរបស់គូភាគីគ្មានទេ ។

-យល់ឃើញថា :ទ្រព្យសម្បត្តិរួមរបស់គូភាគីមានផ្ទះឈើប្រក់សង្ក័សីទំហំ ៤,២០ម x ១៨ម ដីលំនៅដ្ឋានទំហំ ៤,២០ម x ១៨ម ស្ថិតនៅភូមិទី៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឥវ៉ាន់លក់ដូរជាគេសជ្ជៈមួយចំនួន, ម៉ូតូហុងដាសេ១០០ ឆ្នាំ ២០០៤ ចំនួន ០១គ្រឿង, កុំព្យូទ័រ ០១គ្រឿង, ម៉ាស៊ីនព្រីនធ័រ ០១គ្រឿង, ទូរទស្សន៍ពណ៌ចំនួន ០២គ្រឿង, ក្បាលវីស៊ីឌី ០១គ្រឿង, ម៉ាញ៉េ ០១គ្រឿង, ទូរស័ព្ទ ០២គ្រឿង, ទូកញ្ចក់លក់គេសជ្ជៈ, តុបាយចំនួន ០៧គ្រឿង និង តុបង្រៀនសិស្សចំនួន ២០ គូភាគីបានព្រមព្រៀងឯកភាពប្រគល់ទ្រព្យសម្បត្តិរួមឱ្យទៅចុងចម្លើយគ្រប់គ្រងមានម៉ូតូហុងដាសេ ១០០ ឆ្នាំ ២០០៤ ចំនួន ០១គ្រឿង កុំព្យូទ័រ ០១គ្រឿង ម៉ាស៊ីនព្រីនធ័រចំនួន ០១គ្រឿង ទូរទស្សន៍ពណ៌ ០១គ្រឿង តុបង្រៀនចំនួន ២០តុ និង ឱ្យដើមចោទប្រគល់ប្រាក់ ៩០០ដុល្លាអាមេរិកទៅចុងចម្លើយ ឯទ្រព្យរួមក្រៅពីនេះអោយដើមចោទគ្រប់គ្រង និង ទទួលរ៉ាប់រងសងប្រាក់ជំពាក់ ៣០០ដុល្លាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្ដី**

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ **ម មរ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ **ម មរ** និង ចុងចម្លើយឈ្មោះ **ស ខណរ** ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ ដាក់កំហុសលើចុងចម្លើយ ។

៣-ឱ្យឈ្មោះនាង **ម មរ** ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់កូនស្រីឈ្មោះ **ឌ សទទស** អាយុ ០៧ឆ្នាំ អោយទៅដើមចោទចិញ្ចឹមគ្រប់គ្រង និង ប្រគល់កូនស្រីឈ្មោះ **ទ មនន** អាយុ ០៣ឆ្នាំឱ្យទៅចុងចម្លើយចិញ្ចឹមគ្រប់គ្រង តាមការព្រមព្រៀងរបស់គូភាគី ។ ទុកសិទ្ធិឱ្យគូភាគីទៅសួរសុខទុក្ខកូនបាន តាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-ប្រគល់ទ្រព្យសម្បត្តិរួមអោយទៅដើមចោទកាន់កាប់គ្រប់គ្រងមានផ្ទះឈើប្រក់សង្ក័សីទំហំ ៤.២០ម x ១៨ម ដីលំនៅដ្ឋានទំហំ ៤.២០ម x ១៨ម ស្ថិតនៅភូមិទី៦ ឃុំកំពង់ធំ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឥវ៉ាន់លក់ដូរភេសជ្ជៈមួយចំនួន ទូរទស្សន៍ចំនួន ០១គ្រឿង ទូកញ្ចក់លក់ភេសជ្ជៈ និង តុបាយចំនួន ០៧ តាមការព្រមព្រៀងរបស់គូភាគី ។

៦-ប្រគល់ទ្រព្យសម្បត្តិរួមឱ្យទៅចុងចម្លើយកាន់កាប់គ្រប់គ្រងមានម៉ូតូហុងដាសេ១០០ឆ្នាំ ២០០៤ ចំនួន ០១គ្រឿង, កុំព្យូទ័រ ០១គ្រឿង, ម៉ាស៊ីនព្រីនធ័រចំនួន ០១គ្រឿង, ទូរទស្សន៍ពណ៍ ០១គ្រឿង, តុបង្រៀនចំនួន ២០, ក្បាលវីស៊ីឌី ០១គ្រឿង, ម៉ាញ៉េ ០១គ្រឿង, តាមការព្រមព្រៀងឯកភាពរបស់គូភាគី ។

៧-បង្គាប់ឱ្យដើមចោទឈ្មោះ **ម មរ** ប្រគល់ប្រាក់ចំនួន ៩០០ដុល្លាអាមេរិកឱ្យទៅចុងចម្លើយឈ្មោះ **ស ខណរ** និង ឱ្យទទួលរ៉ាប់រងសងប្រាក់ជំពាក់ចំនួន ៣០០ដុល្លាទៅធនាគារអេស៊ីលីដា តាមការព្រមព្រៀងឯកភាពរបស់គូភាគី ។

៨-បង្គាប់អោយចុងចម្លើយឈ្មោះ **ស ខណរ** បង់ប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្នឹង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០រ០០ សរុប ៧.០០០រ០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់រួចហើយ ផុតកំណត់ឧទ្ធរណ៍ឱ្យចុងចម្លើយសងទៅដើមចោទវិញ ។

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគី បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ០២ខែតាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្ត**

[redacted]